


# រាជាណាចក្រដ៏អស្ចារ្យរបស់ព្រះនាងគន្ធបុប្ផា

នៅក្នុងប្រទេសស្វីសខ្ញុំត្រូវបានគេស្គាល់តាំងពីឆ្នាំ១៩៧២ ដែលមានរហស្សនាមថា បេអាតតូសែលឡូ គឺជាថ្លុកកំប្លែងតន្ត្រីដែលលេងឧបករណ៍សែលឡូផងនិងនិទានរឿងខ្លីៗផង។ ខ្ញុំបានលេងភ្លេងជាថ្លុកនេះសំរាប់ក្មេងៗនិងមនុស្សពេញវ័យផងដែរ ។ ក្នុងសាច់រឿងមួយចំនួនគឺខ្ញុំចងក្រងដោយមានរូបគំនូរសាមញ្ញៗ ដែលខ្ញុំគូរដោយផ្ទាល់ដៃ ។ កន្លងមកខ្ញុំបានចងក្រងសៀវភៅរឿងគំនូរខ្លីៗបាន១២ក្បាលហើយ ។ ក្នុងឆ្នាំ១៩៨២ខ្ញុំបានតាក់តែងរឿងមួយដែលមានតួកូនថ្លុកម្នាក់ឈ្មោះស៊ីលវីយ៉ូលីណូកូដវីយ៉ូឡុង។នេះជាសៀវភៅចុងក្រោយរបស់ខ្ញុំដែលត្រូវបានបោះពុម្ពផ្សាយកាលពី២៩ឆ្នាំកន្លងមកម្ល៉េះ។ ឥឡូវនេះគឺជាលើកទីមួយហើយ ដែលកូនសៀវភៅតូចមួយបានវិលត្រឡប់មកជាថ្មីម្តងទៀត។ខ្ញុំបានដាក់បង្ហាញកូនសៀវភៅរឿងមួយនេះជាលើកដំបូងនៅក្នុងឱកាសនៃការសំដែងមហោស្រពសៀកជាតិនៅក្នុងទីក្រុងហ្ស៊ុយរិចនៃប្រទេសស្វីសកាលពីថ្ងៃទី១៣ ឧសភា ២០១៤កន្លងមកនេះ ដើម្បីជាប្រយោជន៍ដល់មន្ទីរពេទ្យគន្ធបុប្ផា។ ចាប់ពីថ្ងៃទី២ខែមិថុនាខាងមុខនេះកូនសៀវភៅរឿងរបស់ខ្ញុំនេះនឹងត្រូវដាក់លក់នៅច្រកចូលនៃមន្ទីរពេទ្យគន្ធបុប្ផាទី៤ភ្នំពេញនិងនៅឯមន្ទីរពេទ្យជ័យវរ្ម័នទី៧ក្នុងខេត្តសៀមរាបអង្គរក្នុងតំលៃ១០ដុល្លារ ដែលមានផ្តល់ជូនបន្ថែមនូវកូនសៀវភៅបកប្រែជាភាសាខ្មែរផង។រាល់តំលៃ១០ដុល្លារនៃថវិកាទាំងអស់ដែលបានពីការលក់សៀវភៅរឿងនេះនឹងត្រូវដាក់បញ្ចូលទៅក្នុងមូលនិធិគន្ធបុប្ផារបស់យើង។

ថ្ងៃទី៣០ ឧសភា ឆ្នាំ ២០១៤

វេជ្ជបណ្ឌិត បេអាត រិចឆ្នឺ ស្ថាបនិកនិងប្រធានមន្ទីរពេទ្យគន្ធបុប្ផា